ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខ : ..............................

# កំណត់ហេតុកិច្ចប្រជុំ
# ស្តីពីកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាពស្របច្បាប់ និងប្រក្រតី របស់អង្គការសហប្រជាជាតិ
## ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកញ្ញា ថ្ងៃទីម្ភៃប្រាំបី វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំអន្តរក្រសួង "ស្តីពីកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពស្របច្បាប់ និងប្រក្រតី របស់អង្គការសហប្រជាជាតិ" ក្រោមអធិបតីភាព **ឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំអាត អគ្គលេខាធិការគ.ជ.ប.ជ តំណាងលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** ។

សមាសភាពចូលរួមសរុបចំនួន ២៩នាក់ (ស្រី ០៧នាក់) រួមមានតំណាងមកពី ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងអង្គការ IOM ។

គោលបំណងនៃកិច្ចប្រជុំគឺ ដើម្បីពិភាក្សាត្រៀមលក្ខណៈសម្រាប់ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពស្របច្បាប់ និងប្រក្រតី របស់អង្គការសហប្រជាជាតិ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ខាងមុខ ។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គលេខាធិការ** បានមានប្រសាសន៍ថា៖ ដោយបានទទួលការណែនាំពី **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** និងដើម្បីរៀបចំសិក្ខាសាលាថ្នាក់ជាតិឲ្យទទួលបានជោគជ័យ យើងត្រូវជួបប្រជុំដើម្បីពិភាក្សាត្រៀមលក្ខណៈជាមុន ដោយត្រូវពិនិត្យមើលរបៀបវារៈ គិតអំពីធាតុចូល និងអ្វីដែលនឹងត្រូវលើកយកមកធ្វើបទបង្ហាញ ។

ជាកិច្ចបន្ត **លោក កេង ម៉េងឡាង តំណាងអង្គការ IOM** បានឡើងធ្វើបទបង្ហាញអំពី កតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពស្របច្បាប់ និងប្រក្រតី របស់អង្គការសហប្រជាជាតិ៖ តាំងពីដើមមកមិនដែលមានឯកសារណាចែងឲ្យបានជាក់ច្បាស់អំពីទេសន្តរប្រវេសន៍ឡើយ គឺមានតែនៅតាមប្រទេសរៀងៗខ្លួន ដូចនេះបានជាមានការស្នើសុំឲ្យបង្កើតកតិកាសញ្ញានេះឡើង នៅមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ដោយបានការសម្រេចជាឯកច្ឆ័នចំនួន ១៩៣ប្រទេស ។ កតិកាសញ្ញានេះមិនទាន់លេចចេញជារូបរាងនៅឡើយទេ ដូចនេះត្រូវការប្រមូលធាតុចូលពីបណ្តាប្រទេសនីមួយៗ ដោយត្រូវរៀបចំសិក្ខាសាលាថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលនៅប្រទេសម៉ិចស៊ីកូ ។ បច្ចុប្បន្នមានប្រទេសជាង៤០ បាន

ពិគ្រោះយោបល់រួចហើយ ហើយសម្រាប់សិក្ខាសាលាថ្នាក់ជាតិនៅកម្ពុជានេះ នឹងលើកយកវិស័យចំនួន០៦ មកធ្វើការពិភាក្សា រួមមាន៖

១. សិទ្ធិមនុស្ស នៃជនទេសន្តរប្រវេសន៍គ្រប់រូប បរិយាប័នសង្គម ទំនាក់ទំនង គ្រប់ទម្រង់នៃការរើសអើង
២. ទេសន្តរប្រវេសន៍មិនប្រក្រតី និងវិធីប្រក្រតី
៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងអភិបាលកិច្ច នៃទេសន្តរប្រវេសន៍ក្នុងគ្រប់ទិដ្ឋភាព
៤. ការរួមចំណែករបស់ជនទេសន្តរប្រវេសន៍ លើគ្រប់វិស័យ នៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព
៥. ការឆ្លើយតបចំពោះកត្តានានា ដែលបណ្តាលឲ្យមានទេន្តរប្រវេសន៍
៦. អំពើរត់ពន្ធជនទេសន្តរប្រវេសន៍ អំពើជួញដូរមនុស្ស និងទម្រង់សហសម័យនៃទាសភាព

**(ក្នុងចំណោមនេះបានកំណត់វិស័យសំខាន់ៗនាំមុខចំនួន០៣ គឺវិស័យទី២ ទី៣ និងទី៦)**

នៅក្នុងរបៀបវារៈនៃអង្គសិក្ខាសាលា នឹងមានការបែកចែកក្រុមពិភាក្សាចំនួន ០៦ក្រុម ដែលក្នុងក្រុមនីមួយៗមាន "អ្នកសម្របសម្រួល គឺជាអ្នកបំផុសសំនួរ" និង "អ្នកធ្វើរបាយការណ៍ គឺបូកសរុបមតិដើម្បីធ្វើបទបង្ហាញ" ហើយនៅក្នុងកិច្ចពិភាក្សានេះ IOM នឹងផ្តល់កម្រងសំណួរ ដើម្បីពិភាក្សាបញ្ចូលជាតុចូល ។

បន្ទាប់មក អង្គប្រជុំបានស្នើឲ្យ IOM ផ្តល់កម្រងសំនួរពិភាក្សានោះមុន ដើម្បីយកទៅពិនិត្យមើល និងស្វែងរកឯកសារពាក់ព័ន្ធ សម្រាប់ត្រៀមលក្ខណៈជាស្រេច ដែលនឹងនាំឲ្យការពិភាក្សាប្រព្រឹត្តទៅដោយរលូន និងមិនខាតពេលវេលា ។ ជាការឆ្លើយតប តំណាងអង្គការ IOM បានឯកភាពផ្តល់កម្រងសំនួរពិភាក្សាជូនភ្លាមៗផងដែរ ។

**ជាទីបញ្ចប់ ឯកឧត្តមអគ្គលេខាធិការ បានបូកសរុបមតិយោបល់ ដូចខាងក្រោម៖**

- សិក្ខាសាលានឹងមានសមាសភាពចូលរួមប្រហែល ១៥០នាក់ ហើយការជ្រើសរើសសមាសភាពចូលរួមនឹងត្រូវគិតទៅតាមវិស័យនីមួយៗ ។
- ក្រុមពិភាក្សាតាមវិស័យនីមួយៗនឹងត្រូវមានរបាយការណ៍សង្ខេបខ្លីសម្រាប់ធ្វើបទបង្ហាញ តែសូមកុំធ្វើបទបង្ហាញជាលក្ខណៈរបាយការណ៍ឆ្នាំ និយាយរួមគឺនិយាយអំពីផលប៉ះពាល់ និងសំណូមពរពាក់ព័ន្ធនឹងវិស័យនីមួយៗ ។
- ឯកភាពគ្នាថានឹងជួបប្រជុំម្តងទៀត នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧ ពេលរសៀល ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ និងសាមសិបនាទីព្រឹក ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧
**អ្នកធ្វើកំណត់ហេតុ**

វ.ស្រី ប៉ាំរតនៈ

គោរពជូន ឯកឧត្តម
អគ្គលេខាធិការ មេត្តាជ្រាបជាព័ត៌មាន ។
ភ្នំពេញ ថ្ងៃទី០២ ខែ១០ ឆ្នាំ២០១៧
**ប្រធានលេខាធិការដ្ឋាន**

**ឧត្តមសេនីយ៍ទោ. គង់~ពុទ្ធី**

បានឃើញ
03/10/17

## សមាសភាពចូលរួមកិច្ចប្រជុំ
## ស្តីពីគតិភាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍
## ប្រកបដោយសុវត្ថិភាពស្របច្បាប់ និងប្រក្រតី
## របស់អង្គការសហប្រជាជាតិ
## ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧

| | | | |
|---|---|---|---|
| ១ - ឯកឧត្តម ឧ.ឯក | ឋោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| ២ - លោកជំទាវ | ហោ ម៉ាលីន | រដ្ឋលេខាធិការ | ក្រសួងកសិកម្ម |
| ៣ - លោកជំទាវ | អ៊ឹង សាង | ទីប្រឹក្សាក្រសួង | ក្រសួងកសិកម្ម |
| ៤ - លោកជំទាវ | ព្រំ សុភី | អនុរដ្ឋលេខាធិការ | ក្រសួងបរិស្ថាន |
| ៥ - លោកស្រី | ឃ្លោក វិចិត្ររដ្ឋា | អនុប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន |
| ៦ - ឯកឧត្តម | ប៉ែន ពេជ្រសាលី | អគ្គនាយក | ក្រសួងយុត្តិធម៌ |
| ៧ - ឯកឧត្តម ឧ.ឯក | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៨ - ឯកឧត្តម ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៩ - លោកជំទាវ ឧ.ឯក | ប៊ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ១០ - ឯកឧត្តម ឧ.ឯក | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ១១ - ឯកឧត្តម ឧ.ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ១២ - លោក | អ៊ឹង វណ្ណថា | ប្រធាននាយកដ្ឋាន | ក្រសួងការបរទេស |
| ១៣ - លោក | ស៊ុំ សុខុន | ជំនួយការល.ជ កែវ ចរិយា | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១៤ - ឧត្តមសេនីយ៍ទោ | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ១៥ - វរសេនីយ៍ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ១៦ - ឧត្តមសេនីយ៍ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ១៧ - ឧត្តមសេនីយ៍ត្រី | ស្រី សាមឌី | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ១៨ - វរសេនីយ៍ត្រី | ហ៊ី រតនៈ | នាយរងការិយាល័យ | គ.ជ.ប.ជ |
| ១៩ - ឧត្តសេនីយ៍ត្រី | ឌី ដាម៉ង់ | អនុប្រធានច្រកទ្វាទី១ | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ២០ - លោក | ជីន ចន | អនុប្រធាននាយកដ្ឋាន | ក្រសួងកិច្ចការនារី |
| ២១ - លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| ២២ - លោក | ជិន អង្គារិទ្ធិ | អនុប្រធាននាយកដ្ឋាន | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| ២៣ - លោក | Troy Dooler | Program Manager | IOM |
| ២៤ - លោក | កេង ម៉េងឡុង | Project Officer | IOM |

រួមនឹងសមាសភាពមួយចំនួនទៀត សរុបរួមចំនួន ២៩នាក់ (ស្រី ០៧នាក់)